■ គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា [SCCRP]

[AFD Grant - CKH-1077-01-S និង CKH-1077-02-T]

AFD

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)

## ករណីសិក្សាលេខ ៨

# ក្រុមអ្នកទិញជីរបស់សហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតជាមួយក្រុមហ៊ុនបាយ័ន ហេរិថេច ហូលឌីង គ្រុប

ថ្ងៃទី ២៨ ខែកម្ភៈ ឆ្នាំ ២០១៨

អ្នកនិពន្ធ៖ Hy Thy (GRET)[9]

GRET Professionals for fair development

## មាតិកា

១. ទិដ្ឋភាពរួម៖ សេចក្តីសង្ខេបអំពីបទពិសោធន៍របស់ក្រុមអ្នកលក់ជីក្នុងសហគមន៍កសិករប្រើប្រាស់ទឹកនៅស្ទឹងជីនិត...... ២

២. ដើមកំណើតនៃសកម្មភាព និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ........ ៣

៣.ដំណើរការអនុវត្តន៍........ ៤

៤.លទ្ធផលប្រតិបត្តិការ........ ៦

៥. ការវិភាគផ្នែកសេដ្ឋកិច្ច ........៧

៦. លទ្ធភាព៖ ចំណុចខ្លាំង ចំណុចខ្សោយ និងការរំពឹងទុកនាពេលអនាគតនៃគំនិតផ្តួចផ្តើម ........ ៩

៧. ការធ្វើសាជាថ្មី និងស្ថានភាពសម្រាប់ការធ្វើជាថ្មី ដោយគ្មានជំនួយរបស់គម្រោង SCCRP........ ១១

## អក្សរកាត់

| | | | |
|---|---|---|---|
| AFD | *ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង* | ISC | មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ |
| BHG | ក្រុមហ៊ុនបាយ័ន ហេរិថេច ហូលឌីង គ្រុប | NGO | អង្គការក្រៅរដ្ឋាភិបាល |
| FO | អង្គការកសិករ | SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| FWN | បណ្តាញកសិករ និងទឹក | SCCRP | គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា |
| FWUC | សហគមន៍កសិករប្រើប្រាស់ទឹក | TA-TAG | ជំនួយបច្ចេកទេសសម្រាប់កិច្ចព្រមព្រៀងត្រីភាគី |
| GRET | *ក្រុមជំនាញសម្រាប់ការអភិវឌ្ឍដោយសមធម៌* | WASP | គម្រោងវិស័យទឹក និងកសិកម្ម |
| IBG | ក្រុមទិញធាតុចូល | | |

[9] www.gret.org

ការប្រកាសមិនទទួលខុសត្រូវ៖ ឯកសារនេះតំណាងឲ្យតែទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះ ហើយមិនមែនជាទស្សនៈរបស់ AFD ឬ SNEC ទេ

# ខ្នាត និងរង្វាស់

| | |
|---|---|
| ha | ហិកតា |
| kg | គីឡូក្រាម |
| KHR | រៀល (ប្រហែល ៤០០០ រៀលស្មើនឹង ១ ដុល្លារអាមេរិក)។ |
| t | តោន (ស្មើនឹង ១០០០ គីឡូក្រាម) |
| USD | ដុល្លាអាមេរិក |

# ១.ទិដ្ឋភាពរួម៖ សេចក្តីសង្ខេបអំពីបទពិសោធន៍របស់ក្រុមអ្នកលក់ជីក្នុងសហគមន៍កសិករប្រើប្រាស់ទឹកនៅស្ទឹងជីនិត

សហគមន៍កសិករប្រើប្រាស់ទឹកនៅស្ទឹងជីនិត (FWUC) មានទីតាំងនៅក្នុងភូមិឈើទាល ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ និងកំពុងគ្រប់គ្រងគម្រោងប្រព័ន្ធធារាសាស្ត្រនៅស្ទឹងជីនិត។ សហគមន៍កសិករប្រើប្រាស់ទឹកនៅស្ទឹងជីនិតបានរៀបចំ "ក្រុមទិញជី" (IBG) ដោយការគាំទ្រពីក្រុមទីផ្សារនៃមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ (ISC) បណ្តាញកសិករ និងទឹក (FWN) និងសេដ្ឋវិទូកសិកម្មនៃក្រុមជំនាញសម្រាប់ការអភិវឌ្ឍដោយសមធម៌។ គេបានអនុវត្តសកម្មភាពនេះកាលពីខែមិថុនា ឆ្នាំ ២០១៦ និងខែមករា ឆ្នាំ ២០១៧ ។

គោលបំណងចម្បងរបស់ក្រុមទិញធាតុចូល គឺដើម្បីទិញធាតុចូលជាមួយតម្លៃទាបជាងអ្វីដែលកសិករចំណាយជាធម្មតា និងទទួលបានបរិមាណត្រឹមត្រូវ និងគុណភាពល្អសម្រាប់សមាជិកក្រុមទិញធាតុចូលទាំងអស់។ ក្រុមទិញធាតុចូលក្នុងសហគមន៍កសិករប្រើប្រាស់ទឹកនៅស្ទឹងជីនិតមានសមាជិក ១៧៤ នាក់ដែលបានទិញជីជប៉ុន។ ពួកគេបានទិញជី ជប៉ុនចំនួន ២៧៦០០ គីឡូក្រាម (សម្រាប់ទឹកប្រាក់ចំនួន ១៦៣៨០,៥០ ដុល្លាអាមេរិក) តាមរយៈក្រុមទិញធាតុចូលពីក្រុមហ៊ុនផ្គត់ផ្គង់មួយឈ្មោះថា បាយ័ន ហេរិថេច ហូលឌីង គ្រុប (BHG) ។

ដោយផ្អែកលើការវិភាគសេដ្ឋកិច្ចកាលពីឆ្នាំ ២០១៦ សមាជិកក្រុមទិញធាតុចូលមានការផ្គត់ផ្គង់ជីក្នុងតម្លៃជាមធ្យម ៦,៥% ទាបជាងកសិករនៅក្នុងតំបន់ក្រៅពីក្រុមទិញធាតុចូល ហើយសហគមន៍កសិករប្រើប្រាស់ទឹក និងបណ្តាញកសិករ និងទឹកក៏អាចទទួលប្រាក់ចំណូលពីអ្នកផ្គត់ផ្គង់ជី (០,៥ ដុល្លាររអាមេរិកក្នុង ៥០ គីឡូក្រាមសម្រាប់សហគមន៍កសិករប្រើប្រាស់ទឹក និង ០,៥ ដុល្លាររអាមេរិកក្នុង ៥០ គីឡូក្រាមសម្រាប់បណ្តាញកសិករ និងទឹក)។

សមាជិកក្រុមទិញធាតុចូល បានបង្ហាញពីការពេញចិត្តរបស់ពួកគេជាមួយសកម្មភាពរបស់សហគមន៍កសិករប្រើប្រាស់ទឹក៖ ក្រុមទិញធាតុចូលនៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតបានសហការជាមួយក្រុមហ៊ុនបាយ័ន ហើយបានអនុវត្តសកម្មភាពខ្លួនយ៉ាងរលូន ដោយមានការចូលរួមយ៉ាងសកម្មពីសមាជិកគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក ប្រធានភូមិ/តំណាងភូមិ និងសមាជិក។ កិច្ចសហការល្អ រវាងសមាជិក និងអ្នកផ្គត់ផ្គង់ក៏ជាកត្តាសំខាន់មួយជំរុញឱ្យដំណើរការនេះទទួលបានជោគជ័យផងដែរ។

ប៉ុន្តែ ក្រៅពីភាពជោគជ័យនៃបទពិសោធន៍សាកល្បងនេះ សមាជិកគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតមិនទាន់បានត្រៀមខ្លួនរួចរាល់ ក្នុងការពង្រីកប្រតិបត្តិការដោយគ្មានការគាំទ្រ (ពីបណ្តាញកសិករ និងទឹក និង

មជ្ឈមណ្ឌលសេវាកម្មធារាសាស្រ្ត) នៅឆ្នាំបន្តបន្ទាប់ទេ។ ពួកគេជឿថា ពួកគេនឹងត្រូវការការគាំទ្រ និងជំនួយបន្ថែមសម្រាប់រយៈពេលមួយ ឬពីរឆ្នាំទៀត។

# ២. ដើមកំណើតនៃសកម្មភាព និងការចូលរួមរបស់ភាគីពាក់ព័ន្ធ

## ២.១ ដើមកំណើតនៃសកម្មភាព

ភ្នាក់ងារអភិវឌ្ឍន៍បារាំងបានផ្តល់មូលនិធិដល់គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា។ គោលបំណង គឺដើម្បីចូលរួមចំណែកក្នុងការគាំទ្រដល់ការអនុវត្តយុទ្ធសាស្រ្តជាតិនៃការផ្សព្វផ្សាយអំពីផលិតកម្មស្រូវ និងការនាំចេញអង្ករដែលបានអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្រ្តីកាលពីខែកក្កដា ឆ្នាំ ២០១០ ក្នុងគោលដៅបង្កើនតម្លៃបន្ថែម និងចំណែកនៃតម្លៃបន្ថែមនេះឱ្យដល់កម្រិតអតិបរមា ដើម្បីឈានដល់អ្នកផលិត ដែលជាផ្នែកមួយនៃគោលដៅរួមក្នុងការកាត់បន្ថយភាពក្រីក្រនៅតាមជនបទ។

គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា បានចុះហត្ថលេខានៅលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយនឹងបណ្តាញកសិករ និងទឹក ដើម្បីគាំទ្រដល់ (ដោយមានជំនួយពីមជ្ឈមណ្ឌលសេវាកម្មធារាសាស្រ្ត និងជំនួយបច្ចេកទេសសម្រាប់កិច្ចព្រមព្រៀងត្រីភាគីរបស់ក្រុមជំនាញសម្រាប់ការអភិវឌ្ឍដោយសមធម៌) ឆន្ទៈសហគមន៍កសិករប្រើប្រាស់ទឹកក្នុងការចូលរួមក្នុងការធ្វើពាណិជ្ជូបនីយកម្មស្រូវ និងការផ្គត់ផ្គង់ធាតុចូល។ គំនិតផ្តួចផ្តើមនៃការរៀបចំក្រុមទិញធាតុចូលនៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតគឺជាផ្នែកមួយនៃភាពជាដៃគូនេះ។

## ២.២. ការចូលរួមរបស់ភាគីពាក់ព័ន្ធសំខាន់ៗ

### សហគមន៍កសិករប្រើប្រាស់ទឹកនៅស្ទឹងជីនិត

សហគមន៍កសិករប្រើប្រាស់ស្ទឹងជីនិតស្ទឹងជីនិតបានចុះបញ្ជីនៅក្រសួងធនធានទឹក និងឧតុនិយមកាលឆ្នាំ ២០០៦ ។ សហគមន៍នេះគ្រប់គ្រងប្រព័ន្ធធារាសាស្រ្តនៅស្ទឹងជីនិតដែលជាតំបន់ស្រោចស្រពគ្របដណ្តប់លើ ២៥ ភូមិក្នុង ៣ ឃុំនៅស្រុកសន្ទុក ខេត្តកំពង់ធំ។ ប្រព័ន្ធធារាសាស្រ្តនេះគ្របដណ្តប់លើផ្ទៃដីចំនួន ២៨០២,៤៥ ហិកតាក្នុង ៥៨ ប្លុក។ មានស្រែចំនួន ៩០០៥ និងក្រុមគ្រួសារកសិករចំនួន ២៨៧៨ គ្រួសារ។ អង្គភាពគ្រប់គ្រង សហគមន៍កសិករប្រើប្រាស់ស្ទឹងជីនិតមានសមាជិកគណៈកម្មាធិការចំនួន ៤ នាក់ និងតំណាងអ្នកភូមិចំនួន ២៥ នាក់ ហើយសហគមន៍កសិករប្រើប្រាស់ទឹកមានបុគ្គលិកចំនួន ៤ នាក់។

### មជ្ឈមណ្ឌលសេវាកម្មធារាសាស្រ្ត (ISC)

មជ្ឈមណ្ឌលសេវាកម្មធារាសាស្រ្ត (ISC) ជាអង្គការកម្ពុជាមួយដែលមានឯកទេសផ្តល់សេវាកម្ម កសាងសមត្ថភាព និងគាំទ្រដល់សហគមន៍កសិករប្រើប្រាស់ទឹក និងគម្រោងដែលពាក់ព័ន្ធទៅនឹងវិស័យធារាសាស្រ្ត។ ជាផ្នែកមួយនៃគម្រោង SCCRP គឺមជ្ឈមណ្ឌល ISC អនុវត្តសកម្មភាពពីរប្រភេទ៖ ១) ផ្តល់ជំនួយដោយផ្ទាល់ដល់សមាជិក និងលេខាធិការនៃ

គណៈកម្មការធិការសហគមន៍កសិករប្រើប្រាស់ទឹក និង ២)ផ្តល់ជំនួយសេវាកម្មដល់សហគមន៍កសិករប្រើប្រាស់ទឹកដើម្បីឱ្យចូលរួមនៅក្នុងម៉ូដែលក្រុម PSG និងក្រុម IBG ។

### បណ្តាញកសិករ និងទឹក (FWN)

បណ្តាញកសិករ និងទឹក (FWN) គឺជាសហព័ន្ធតំណាងរបស់សហគមន៍កសិករប្រើប្រាស់ទឹកនៅកម្ពុជា។ បណ្តាញនេះត្រូវបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃតាំងពី ២០១១ មកម្ល៉េះ។ នាពេលបច្ចុប្បន្ន បណ្តាញកសិករ និងទឹកមានសមាជិកចំនួន ២៦ (សហគមន៍កសិករប្រើប្រាស់ទឹកចំនួន ២៦ ដែលប្រមូលផ្តុំគ្រួសារចំនួន ៣៤ ៩៥៨ ជាមួយដីស្រែសរុបចំនួន ៤១ ៩៨០ ហិកតានៅក្នុងខេត្តចំនួន ១១)។

### ជំនួយបច្ចេកទេសសម្រាប់កិច្ចព្រមព្រៀងត្រីភាគី (TA-TAG)

**TA-TAG** គឺជាក្រុមរបស់ GRET ដែលមានតួនាទីគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងត្រីភាគី (MOWRAM, ISC និង FWN) ជាផ្នែកមួយនៃគម្រោងមួយទៀតដែលមានការគាំទ្រពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ដែលមានឈ្មោះថា គម្រោងវិស័យទឹក និងកសិកម្ម។ GRET គឺជាអង្គការមិនមែនរដ្ឋាភិបាលរបស់បារាំង ដែលបានបង្កើតឡើងតាំងពីឆ្នាំ ១៩៧៦ ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងវិសមភាពនៅក្នុងវិស័យនេះ និងក្នុងគោលនយោបាយ។ អ្នកជំនាញរបស់អង្គការនេះធ្វើអន្តរាគមន៍នៅក្នុងវិស័យជាច្រើន ដើម្បីផ្តល់ដំណោះស្រាយបានយូរអង្វែងប្រកបដោយភាពច្នៃប្រឌិតសម្រាប់ការអភិវឌ្ឍដោយសមភាព។ នៅកម្ពុជា GRET បានធ្វើសកម្មភាពនានាអស់រយៈពេលជាង ២០ ឆ្នាំមកហើយ ជាពិសេសនៅក្នុងវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ។

### ក្រុមហ៊ុន បាយ័ន ហេរិថេច ហូលឌីង គ្រុប (អ្នកផ្គត់ផ្គង់)

ក្រុមហ៊ុនបាយ័ន ហេរិថេច ហូលឌីង គ្រុប គឺជានីតិបុគ្គលពាណិជ្ជកម្មឯកជនមួយ ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញប្រទេសកម្ពុជា។ ក្រុមហ៊ុនបាយ័ន ហេរិថេច ហូលឌីង គ្រុប ប្រមូលផ្តុំក្រុមហ៊ុនចំនួនបួន ដែលក្នុងនោះមានក្រុមហ៊ុនពីរធ្វើការពាក់ព័ន្ធនឹងការនាំចូលជី និងការធ្វើពាណិជ្ជូបនីយកម្ម។ សកម្មភាពរបស់ក្រុមហ៊ុននេះក៏រួមបញ្ចូលសកម្មភាពផ្សេងទៀតក្នុងវិស័យកសិកម្មផងដែរ ជាពិសេសការនាំចេញអង្ករ ដំឡូងមី និងកៅស៊ូ។

## ៣. ដំណើរការអនុវត្តន៍

ជំហានសំខាន់ៗនៃការអនុវត្តប្រតិបត្តិការ "ក្រុមទិញជី" សាកល្បងនៅសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិត មានបង្ហាញដូចខាងក្រោម៖

### ជំហានទី ១៖ ការស្វែងរកអ្នកផ្គត់ផ្គង់

- បណ្តាញកសិករ និងទឹកបានចូលរួមក្នុងការស្វែងរកអ្នកផ្គត់ផ្គង់ជី។ មុនពេលអនុវត្តការគាំទ្រនេះដល់ក្រុមទិញធាតុចូលរបស់ FWUC ស្ទឹងជីនិត គឺ FWN បានបង្កើតទំនាក់ទំនងជាមួយក្រុមហ៊ុនបាយ័ន ហេរិថេច និងបានធ្វើពង្រាងអនុស្សរណៈនៃការយោគយល់គ្នាសម្រាប់ការផ្គត់ផ្គង់ជីជប៉ុន ប៉ុន្តែពេលនោះមិនទាន់ចុះហត្ថលេខានៅឡើយ ។

### ជំហានទី ២៖ ការបង្កើតក្រុមទិញជាតុចូល (IBG)

- ក្រុមហ៊ុនបាយ័ន និង FWUC បានរៀបចំកិច្ចប្រជុំជាមួយសមាជិក FWUC ដើម្បីបង្ហាញអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ជីជប៉ុន
- FWUC (ដោយមានការគាំទ្រពី ISC) បានចាប់ផ្តើមកំណត់អត្តសញ្ញាណកសិករដែលមានចំណាប់អារម្មណ៍ចំពោះក្រុមទិញជីជប៉ុន តាមរយៈកិច្ចប្រជុំ និងទំនាក់ទំនងបុគ្គល។ ព័ត៌មានទាក់ទងនឹងកសិករដែលមានចំណាប់អារម្មណ៍ត្រូវបានចងក្រងដោយប្រើប្រាស់គំរូបញ្ជីបញ្ជាទិញរបស់កសិករ ដែលបានបង្កើតឡើងដោយ ISC/GRET ។

### ជំហានទី ៣៖ ការរៀបចំមុនពេលទិញជាតុចូល

- ISC បានជួយ FWUC ពាក់ព័ន្ធនឹងការបញ្ចូលទិន្នន័យក្នុងឯកសារ Excel និងការគ្រប់គ្រងទិន្នន័យរបស់ IBG
- ISC បានបញ្ជាទិញជីជប៉ុនឱ្យក្រុមហ៊ុនបាយ័ន ដោយផ្អែកតាមការបញ្ជាទិញរបស់កសិករដែលបានចងក្រង។

### ជំហានទី ៤៖ ប្រតិបត្តិការ អំឡុងពេលទិញជាតុចូល

- ក្រុមហ៊ុនបាយ័ន បានចែកចាយជីជប៉ុនជាមួយនឹងវិក្កយបត្រ។
- ចំពោះការទូទាត់ជាសាច់ប្រាក់ (កសិករអាចទូទាត់ដោយផ្ទាល់ទៅក្រុមហ៊ុនបាយ័ន បន្ទាប់មកក្រុមហ៊ុនបាយ័នប្រគល់វិក្កយបត្រទៅ FWUC) ឬ (កសិករអាចទូទាត់ដោយផ្ទាល់ទៅ FWUC បន្ទាប់មក FWUC កត់ត្រាលើឯកសារ និងឱ្យក្រុមហ៊ុនបាយ័ន មកយកប្រាក់ក៏បាន) ។
- សម្រាប់ការទិញជីជប៉ុនជាឥណទាន ទម្រង់បែបបទនៃការចុះបញ្ជី (តារាង) ត្រូវបានបង្កើតឡើង៖ "បញ្ជីកសិករដែលទិញជីជប៉ុនជាឥណទាន" ដែលត្រូវកត់ត្រាដូចជា៖ ឈ្មោះកសិករ បរិមាណដែលទិញ តម្លៃឯកតា តម្លៃសរុបជាដើម។ បន្ទាប់ពីបំពេញតារាងនេះរួច កសិករម្នាក់ៗត្រូវទទួលស្គាល់តម្លៃ និងបរិមាណជីដែលខ្លួនបានទទួល ដោយការផ្តិតស្នាមមេដៃរបស់ខ្លួននៅលើបញ្ជី។ បន្ទាប់មក ក្រុមហ៊ុនបាយ័ន និង FWUC ស៊ីនជីនិតនឹងចុះហត្ថលេខាលើកិច្ចសន្យានេះ ដោយផ្អែកលើកំណត់ត្រាទាំងនេះ។

### ជំហានទី ៥៖ ប្រតិបត្តិការ ក្រោយពីទិញជាតុចូល

- FWUC និង ISC បានរៀបចំកិច្ចប្រជុំជាមួយក្រុមហ៊ុនបាយ័ន ដើម្បីផ្ទៀងផ្ទាត់បរិមាណសរុប
- ក្រុមហ៊ុនបាយ័ន បានរំឭក FWUC អំពីពេលវេលាបង់ប្រាក់
- FWUC បានរំឭកសមាជិកអំពីពេលវេលាបង់ប្រាក់
- FWUC បានប្រមូលប្រាក់ ហើយ FWUC បានហៅក្រុមហ៊ុនបាយ័ន មកទទួលយកប្រាក់
- ចុងបញ្ចប់ មានការរៀបចំឡើងនូវកិច្ចប្រជុំរបស់ក្រុមទិញជាតុចូលជាមួយសមាជិក ដើម្បីបង្ហាញអំពីលទ្ធផលរួមមានបទពិសោធន៍ដែលបានពីសកម្មភាពរបស់ក្រុមទិញជាតុចូល និងដើម្បីរៀបចំដំណាក់កាលបន្ទាប់នៃការអនុវត្តរបស់ក្រុមទិញជាតុចូល។

# ៤. លទ្ធផលប្រតិបត្តិការ

បន្ទាប់ពីក្រុមហ៊ុនបាយ័ន និងបណ្តាញកសិករ និងទឹក បានធ្វើសេចក្តីព្រាងលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការផ្គត់ផ្គង់ជីជប៉ុនរួចមក ក្រុមហ៊ុនបាយ័ន និងសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតបានរៀបចំកិច្ចប្រជុំជាមួយសមាជិកសមាគមន៍នេះនៅថ្នាក់ភូមិ ដើម្បីបង្ហាញពីអត្ថប្រយោជន៍នៃការប្រើប្រាស់ជីជប៉ុន។ បន្ទាប់មក ដោយមានការគាំទ្រពីមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ សហគមន៍នេះបានចាប់ផ្តើមកំណត់អត្តសញ្ញាណកសិករដែលចាប់អារម្មណ៍ចំពោះក្រុមទិញជីជប៉ុន។ ជាលទ្ធផល កសិករ ១៧៤ នាក់បានទិញជីរបស់ក្រុមហ៊ុនបាយ័ន ហោរិថេច ចំនួន ២៧៦០០ គីឡូក្រាម(ក្នុងតម្លៃ ១៦៣៨០,៥០ ដុល្លារអាមេរិក) តាមរយៈក្រុមទិញជាតុចូល។ មានតែសមាជិកសហគមន៍កសិករប្រើប្រាស់ទឹកមួយផ្នែកប៉ុណ្ណោះ ដែលបានចូលរួមក្នុងក្រុមទិញជាតុចូលដោយសារមូលហេតុដូចខាងក្រោម៖

- សមាជិកសហគមន៍កសិករប្រើប្រាស់ទឹកមួយចំនួនបានទិញជីរួចមកហើយ មុនពេលមានប្រតិបត្តិការនេះ
- សមាជិកសហគមន៍កសិករប្រើប្រាស់ទឹកមួយចំនួនមិនបានស្នាក់នៅផ្ទះទេ អំឡុងពេលធ្វើផែនការទិញ
- សមាជិកសហគមន៍កសិករប្រើប្រាស់ទឹកមួយចំនួនមិនបានជឿទុកចិត្តជីជប៉ុនរបស់ក្រុមហ៊ុនបាយ័នទេ
- សមាជិកសហគមន៍កសិករប្រើប្រាស់ទឹកមួយចំនួនមិនបានជឿទុកចិត្តក្រុមទិញជាតុចូលទេ ព្រោះនេះជាលើកដំបូងនៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិត
- សមាជិកសហគមន៍កសិករប្រើប្រាស់ទឹកមួយចំនួនត្រូវការជីផ្សេងទៀតដែលខុសពីជីជប៉ុន
- សមាជិកសហគមន៍កសិករប្រើប្រាស់ទឹកមួយចំនួនគិតថាជីជប៉ុនមានតម្លៃថ្លៃ បើប្រៀបធៀបនឹងជីផ្សេងៗ។

ផ្អែកលើការវិភាគសេដ្ឋកិច្ចសម្រាប់ការអនុវត្តកាលឆ្នាំ ២០១៦ តម្លៃដែលសមាជិកក្រុមទិញជាតុចូលបានចំណាយលើជីជាមធ្យម ៦,៥% គឺទាបជាងតម្លៃដែលកសិករដទៃទៀតបានចំណាយ (នៅក្នុងទីតាំងដូចគ្នា) ក្រៅក្រុមទិញជាតុចូល។ សម្រាប់សមាជិកក្រុមទិញជាតុចូល ១៧៤ នាក់ គឺសន្សំប្រាក់បាន ៩៩២ ដុល្លារអាមេរិកចំពោះថ្លៃចំណាយផលិតកម្មសម្រាប់ការទិញជីចំនួន ២៧,៦ តោន។

អត្ថប្រយោជន៍សម្រាប់សហគមន៍កសិករប្រើប្រាស់ទឹកក្នុងការបើកដំណើរការសេវារបស់ខ្លួនគឺ សហគកមន៍នេះទទួលបានអំណាចចរចា ដែលកែលម្អការគាំទ្ររបស់សមាជិក បង្កើតទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការល្អជាមួយសមាជិក និងអ្នកផ្គត់ផ្គង់ ហើយអាចបង្កើតចំណូលផងដែរ។ លើសពីនេះទៀត សហគមន៍នេះអាចទទួលបានប្រាក់ចំណូលសរុបចំនួន ២៧៦ ដុល្លារអាមេរិក (០,៥០ ដុល្លារអាមេរិកក្នុង ៥០ គីឡូក្រាម) ពីក្រុមហ៊ុន។ បន្ទាប់មកសហគមន៍កសិករប្រើប្រាស់ទឹកបានចំណាយ ៥០% នៃប្រាក់ចំណូលសរុប (ដោយផ្អែកលើគោលការណ៍ដែលសហគមន៍នេះបានសម្រេច) ចំពោះថ្លៃឈ្នួលពលកម្មរបស់អ្នកទទួលបន្ទុកអនុវត្តដូចជាតំណាងភូមិ ប្រធានភូមិ និងសមាជិកគណៈកម្មាធិការនៃសហគមន៍កសិករប្រើប្រាស់ទឹក។ សេវាកម្មថ្មីនេះអាចធ្វើឱ្យមានតុល្យភាពលើថ្លៃចំណាយរបស់សហគមន៍កសិករប្រើប្រាស់ទឹក និងធ្វើឱ្យសហគមន៍នេះអាចដំណើរការល្អប្រសើរជាងមុន ដោយសារការចំណាយរបស់សហគមន៍សម្រាប់ប្រតិបត្តិការនេះគឺ ៥០% នៃប្រាក់ចំណូលសរុប។ ដោយអនុលោមតាមគោលការណ៍ដែលសម្រេចដោយសហគមន៍កសិករប្រើប្រាស់ទឹក នោះទឹកប្រាក់ចំណេញដែលបានមកពីសកម្មភាពរបស់ក្រុមទិញជាតុចូល គឺត្រូវបានប្រើប្រាស់សម្រាប់សកម្មភាពទូទៅរបស់សហគមន៍កសិករប្រើប្រាស់ទឹក។

បន្ថែមពីនេះទៀត បណ្ដាញកសិករ និងទឹក ក៏អាចទទួលបានចំណូល ២៧៦ ដុល្លារអាមេរិក (០,៥០ ដុល្លារអាមេរិកក្នុង ៥០ គីឡូក្រាម) ពីក្រុមហ៊ុន។ ក្រុមទិញធាតុចូលក្នុងសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតដែលសហការជាមួយក្រុមហ៊ុនបាយ័នដោយដំណើរការយ៉ាងរលូនដោយការចូលរួមយ៉ាងល្អពីសមាជិកគណៈកម្មាធិការនៃសហគមន៍កសិករប្រើប្រាស់ទឹក ប្រធានភូមិ/តំណាងភូមិ និងសមាជិក។ មានការសហការល្អរវាងសមាជិក ប្រធានភូមិ/តំណាងភូមិ និងសមាជិកគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក និងអ្នកផ្គត់ផ្គង់។ នៅទីបំផុត សមាជិកក្រុមទិញធាតុចូលបានពេញចិត្តនឹងសកម្មភាពរបស់សហគមន៍កសិករប្រើប្រាស់ទឹក និងទទួលស្គាល់ពីអត្ថប្រយោជន៍ដែលពួកគេទទួលបានពីក្រុមទិញធាតុចូល។



ប៉ុន្តែ ទោះបីជាមានបទពិសោធន៍សាកល្បងប្រកបដោយជោគជ័យក៏ដោយ ក៏សមាជិកគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតមិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការពង្រីកប្រតិបត្តិការដោយគ្មានការគាំទ្រ (ពីបណ្ដាញកសិករ និងទឹក និងមជ្ឈមណ្ឌលធារាសាស្ត្រ) នៅឆ្នាំបន្ទាប់ឡើយ។ ពួកគេជឿជាក់ថា ពួកគេនឹងត្រូវការជំនួយ និងការគាំទ្របន្ថែមសម្រាប់រយៈពេលមួយ ឬពីរឆ្នាំទៀត។

# ៥. ការវិភាគផ្នែកសេដ្ឋកិច្ច

ការវិភាគផ្នែកសេដ្ឋកិច្ចសម្រាប់សកម្មភាពនៃក្រុមទិញធាតុចូលរបស់សហគមន៍កសិករប្រើប្រាស់ទឹក បានផ្ដោតទៅលើសហគមន៍កសិករប្រើប្រាស់ទឹក សមាជិកក្រុមទិញធាតុចូល និងមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ/បណ្ដាញកសិករ និងទឹក។

## ៥.១. ការវិភាគលើលទ្ធផលសេដ្ឋកិច្ចនៅកម្រិតសហគមន៍កសិករប្រើប្រាស់ទឹក

សហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតទទួលបានចំណូលសរុប ២៧៦ ដុល្លារអាមេរិក ពីសកម្មភាពរបស់ក្រុមទិញធាតុចូល។ ម៉្យាងទៀត ការចំណាយលើសកម្មភាពទិញជីនេះបានឈានដល់ទឹកប្រាក់សរុប ១៣៨ ដុល្លារអាមេរិក (មានន័យថា ៥០% នៃចំណូលសរុបដែលសហគមន៍បានផ្ដល់ឱ្យតំណាងភូមិ/មេភូមិ/សមាជិកគណៈកម្មាធិការសម្រាប់ថ្លៃពលកម្ម)។ ដូចនេះ ប្រាក់ចំណេញដែលសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតទទួលបានពីសកម្មភាពក្រុមទិញធាតុចូលគឺ ១៣៨ ដុល្លារអាមេរិក។

ព័ត៌មានលម្អិតមានក្នុងតារាងលេខ ១ ខាងក្រោម។

**តារាងលេខ ១៖ ចំណូល និងចំណាយនៃប្រតិបត្តិការក្រុមទិញជីនៅកម្រិតសហគមន៍កសិករប្រើប្រាស់ទឹកនៅស្ទឹងជីនិត**

| | | | |
|---|---|---|---|
| I. | **ចំណូលរបស់សហគមន៍បានមកពីក្រុមទិញជី** | | **២៧៦ ដុល្លារ** |
| | ១.១. ជីគ្រាប់ (៤៣៣ បាវ X ២ ០០០ រៀល) | ២១៦,៥០ ដុល្លារ | |
| | ១.២. ជីម្សៅ (៧ បាវ x ២ ០០០ រៀល) | ៣,៥០ ដុល្លារ | |
| | ១.៣. ជីអ៊ុយរេ (២២៤ បាវ x ១ ០០០ រៀល) | ៥៦,០០ ដុល្លារ | |
| II. | **ការចំណាយរបស់សហគមន៍សម្រាប់ក្រុមទិញជី** | | **១៣៨ ដុល្លារ** |
| | ២.១. តំណាងភូមិ - ជីគ្រាប់ (១ ០០០ រៀល / បាវ) | ១០៨,២៥ ដុល្លារ | |
| | ២.២. តំណាងភូមិ - ជីម្សៅ (១ ០០០ រៀល / បាវ) | ១,៧៥ ដុល្លារ | |
| | ២.៣. តំណាងភូមិ - ជីអ៊ុយរេ (៥០០ រៀល / បាវ) | ២៨ ដុល្លារ | |
| III. | **ប្រាក់ចំណេញរបស់សហគមន៍បានមកពីក្រុមទិញជី** | | **១៣៨ ដុល្លារ** |

<u>ចំណាំ៖</u> សម្រាប់ក្រុមទិញជាតុចូលនៃសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិត អ្នកផ្គត់ផ្គង់បានផ្តល់កម្រៃជើងសារដល់សហគមន៍ និងបណ្តាញកសិករ និងទឹក ដូចខាងក្រោម៖

- សហគមន៍កសិករប្រើប្រាស់ទឹក អាចទទួលបាន ០,៥០ ដុល្លារអាមេរិក ក្នុងមួយបាវ ៥០ គ.ក្រ (សម្រាប់ជីគ្រាប់ ឬជីម្សៅ) និង ០,២៥ ដុល្លារអាមេរិក ក្នុងមួយបាវ ២៥ គ.ក្រ (សម្រាប់ជីអ៊ុយរេ)។
- បណ្តាញកសិករ និងទឹក អាចទទួលបាន ០,៥០ ដុល្លារអាមេរិក ក្នុងមួយបាវ ៥០ គ.ក្រ (សម្រាប់ជីគ្រាប់ ឬជីម្សៅ) និង ០,២៥ ដុល្លារអាមេរិក ក្នុងមួយបាវ ២៥ គ.ក្រ (សម្រាប់ជីអ៊ុយរេ)។

## ៥.២. ការវិភាគលើលទ្ធផលសេដ្ឋកិច្ចសម្រាប់សមាជិកក្រុមទិញជាតុចូល

ប្រសិនបើកសិករម្នាក់ៗទិញជីក្នុងបរិមាណដូចគ្នា (២៧ ៦០០ គ.ក្រ) ពីអ្នកផ្គត់ផ្គង់ក្នុងមូលដ្ឋាន គេបានប៉ាន់ស្មានថា កសិករនឹងចំណាយអស់ ១៧ ៣៧២,៥០ ដុល្លារអាមេរិក។ ចំណែកនៅក្នុងក្រុមទិញចូលវិញ កសិករត្រូវចំណាយត្រឹមតែ ១៦ ៣៨០,៥០ ដុល្លារអាមេរិកប៉ុណ្ណោះ។ ដូចនេះ កសិករសន្សំបាន ៩៩២ ដុល្លារអាមេរិក (ប្រហែល ១៤៤ រៀល/គ.ក្រ) ដោយការទិញរួមគ្នាតាមរយៈក្រុមទិញជាតុចូល។ ព័ត៌មានលម្អិតមាននៅក្នុងតារាងលេខ ២ ខាងក្រោម។

**តារាង ២ ៖ តម្លៃដែលកសិករទទួលបាននៅក្រុមទិញជាតុចូល និងការប្រៀបធៀបតម្លៃដែលកសិករទទួលបានក្រៅក្រុមទិញជាតុចូល**

| | | | |
|---|---|---|---|
| I. | **ទឹកប្រាក់ដែលសមាជិកក្រុមទិញជាតុចំណាយលើការទិញរបស់ពួកគេ (២៧ ៦០០ គ.ក្រ)** | | **១៦ ៣៨០,៥០ ដុល្លារ** |
| | ១.១. ជីគ្រាប់ (៤៣៣ បាវ x ១១៧ ០០០ រៀល) | ១២ ៦៦៥,២៥ ដុល្លារ | |
| | ១.២. ជីម៉្សៅ (៧ បាវ x ១០៧ ០០០ រៀល) | ១៨៧,២ ដុល្លារ | |
| | ១.៣. ជីអ៊ុយរេ (២២៤ បាវ x ៦៣ ០០០ រៀល) | ៣ ៥២៨ ដុល្លារ | |
| II. | **ទឹកប្រាក់ដែលកសិករនឹងចំណាយសម្រាប់បរិមាណដូចគ្នា (២៧៦០០ គ.ក្រ) ក្រៅក្រុមទិញជាតុចូល (ដោយផ្អែកលើថ្លៃអ្នកផ្គត់ផ្គង់ក្នុងមូលដ្ឋានផ្តល់ឱ្យក្នុងរយៈពេលដូចគ្នា)** | | **១៧ ៣៧២,៥០ ដុល្លារ** |
| | ២.១. ជីគ្រាប់ (៤៣៣ បាវ x ១២៥ ០០០ រៀល) | ១៣ ៥៣១,២៥ ដុល្លារ | |
| | ២.២. ជីម្សៅ (៧ បាវ x ១១៥ ០០០ រៀល) | ២០១,២៥ ដុល្លារ | |
| | ២.៣. ជីអ៊ុយរេ (២២៤ បាវ x ៦៥ ០០០ រៀល) | ៣ ៦៤០ ដុល្លារ | |
| III. | **ប្រាក់ចំណេញរបស់សមាជិកក្រុមទិញជាតុចូលលើការទិញជី (២៧ ៦០០ គ.ក្រ)** | | **៩៩២ ដុល្លារ** |

### ៥.៣. ការវិភាគសេដ្ឋកិច្ចសម្រាប់មជ្ឈមណ្ឌលសេវាកម្មធារាសាស្រ្ត/បណ្តាញកសិករ និងទឹក

មជ្ឈមណ្ឌលសេវាកម្មធារាសាស្រ្តបានប្រើប្រាស់បុគ្គលិកចំនួន ៣ នាក់ (មានអ្នកជំនាញទីផ្សារម្នាក់ មន្ត្រីផ្នែកទីផ្សារម្នាក់ និងអ្នកសម្របសម្រួលវិស័យម្នាក់) ដើម្បីគាំទ្រដល់បណ្តាញកសិករ និងទឹកស្អឹងជីនិត លើសកម្មភាពរបស់ក្រុមទិញធាតុចូល កាលពីខែមិថុនា ឆ្នាំ ២០១៦ និងខែមករា ឆ្នាំ ២០១៧ ។ រយៈពេលធ្វើការសរុបដែលបានប្រើសម្រាប់សកម្មភាពនេះ គឺ ២៤ ថ្ងៃនៃថ្ងៃធ្វើការ។ ថ្លៃចំណាយលើប្រតិបត្តិការរបស់មជ្ឈមណ្ឌលសម្រាប់គាំទ្រដល់ក្រុមទិញ នៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹកស្អឹងជីនិតមានចំនួន ៧៨២ ដុល្លារអាមេរិក សម្រាប់រយៈពេលធ្វើការសរុប។ ថ្លៃចំណាយលើប្រតិបត្តិការរបស់មជ្ឈមណ្ឌល ត្រូវបានគ្របដណ្តប់ដោយការឧបត្ថម្ភធនរបស់គម្រោង។

## ៦. លទ្ធភាព៖ ចំណុចខ្លាំង ចំណុចខ្សោយ និងការរំពឹងទុកនាពេលអនាគតនៃគំនិតផ្តួចផ្តើម

### ៦.១. ការវិភាគលើការរួចដើមនៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹកស្អឹងជីនិត

ដើម្បីធ្វើការវិភាគលើការរួចដើមរបស់ក្រុមទិញធាតុចូលនៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹកស្អឹងជីនិត យើងត្រូវដឹងអំពីថ្លៃចំណាយថេរសរុប ថ្លៃចំណាយអថេរក្នុងមួយតោន ប្រាក់ចំណូលក្នុងមួយតោន និងបរិមាណជីសរុបដែលទិញ។

- ថ្លៃចំណាយថេរសរុប= 0 ដុល្លារអាមេរិក (ឧ. ក្រុមហ៊ុនរ៉ាប់រងថ្លៃចំណាយពាក់ព័ន្ធនឹងកិច្ចប្រជុំនៅកម្រិតភូមិ)[២]
- ថ្លៃចំណាយអថេរក្នុងមួយតោន= ៥ ដុល្លារអាមេរិក
- ប្រាក់ចំណូលរបស់សហគមន៍ក្នុងមួយតោន= ១០ ដុល្លារអាមេរិក
- បរិមាណជីដែលទិញ= ២៧.៦ តោន

ដោយសារគេមិនមានថ្លៃចំណាយថេរដែលរ៉ាប់រងដោយក្រុមទិញធាតុចូលរបស់សហគមន៍ (ដូចបានបង្ហាញនៅតារាងលេខ ៣ ខាងក្រោម) ការរួចដើមគឺ 0 តោន។ ប្រសិនបើវាអាចមានបរិមាណជីដែលបានទិញ នោះសហគមន៍អាចទទួលបានប្រាក់ចំណេញ។



[២] ថ្លៃចំណាយនៃការគាំទ្ររបស់មជ្ឈមណ្ឌលសេវាកម្មធារាសាស្រ្តមិនត្រូវបានដាក់បញ្ចូលនៅទីនេះទេ ដោយគេចាត់ទុកវាថា នៅក្នុងដំណើរការរយៈពេលវែង សហគមន៍អាចគ្រប់គ្រងសកម្មភាពដោយខ្លួនឯងបាន។

**តារាងលេខ ៣៖ ការវិភាគលម្អិតលើការរួចដើមសម្រាប់ក្រុមទិញធាតុចូលរបស់សហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិត**

| បរិមាណដែលទិញ (តោន) | ប្រាក់ចំណូល FWUC | ថ្លៃចំណាយអថេរ | ថ្លៃចំណាយថេរ | ថ្លៃចំណាយសរុប | ប្រាក់ចំណូលប្រតិបត្តិការ | |
|---|---|---|---|---|---|---|
| ០ តោន | ០ $ | ០ $ | ០ $ | ០ $ | ០ $ | → ការរួចដើម |
| ៥ តោន | ៥០ $ | ២៥ $ | ០ $ | ២៥ $ | ២៥ $ | |
| ១០ តោន | ១០០ $ | ៥០ $ | ០ $ | ៥០ $ | ៥០ $ | |
| ១៥ តោន | ១៥០ $ | ៧៥ $ | ០ $ | ៧៥ $ | ៧៥ $ | |
| ២០ តោន | ២០០ $ | ១០០ $ | ០ $ | ១០០ $ | ១០០ $ | |
| ២៥ តោន | ២៥០ $ | ១២៥ $ | ០ $ | ១២៥ $ | ១២៥ $ | |
| ២៧.៦ តោន | ២៧៦ $ | ១៣៨ $ | ០ $ | ១៣៨ $ | ១៣៨ $ | → តួលេខជាក់ស្តែងសម្រាប់ឆ្នាំ ២០១៦ |
| ៣០ តោន | ៣០០ $ | ១៥០ $ | ០ $ | ១៥០ $ | ១៥០ $ | |
| ៣៥ តោន | ៣៥០ $ | ១៧៥ $ | ០ $ | ១៧៥ $ | ១៧៥ $ | |
| ៤០ តោន | ៤០០ $ | ២០០ $ | ០ $ | ២០០ $ | ២០០ $ | |

យោងតាមលក្ខខណ្ឌរបស់ក្រុមហ៊ុនបាយ័ន ក្រុមហ៊ុនត្រូវដឹកជញ្ជូនជីចំនួន ២ តោន (វាស្មើនឹងមួយឡានដឹកទំនិញធុនតូច) ជាអប្បបរិមា។ នៅសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិត កសិករម្នាក់ត្រូវការជីជប៉ុនយ៉ាងតិច ១០០ គីឡូក្រាម (រួមមាន ជីអ៊ុយរេចំនួន ២ ប៉ាវ = ៥០ គីឡូក្រាម និងជីគ្រាប់ ១ ប៉ាវ = ៥០ គីឡូក្រាម) ។ ដូច្នេះ ពួកគេត្រូវមានកសិករចូលរួមយ៉ាងហោចណាស់ ២០ នាក់ ដើម្បីបំពេញតម្រូវការជីប្រហែលជា ២ តោន ទើបអាចដំណើរការសកម្មភាពរបស់ក្រុមទិញធាតុចូលបាន។

ថ្លៃចំណាយលើប្រតិបត្តិការរបស់មជ្ឈមណ្ឌល សម្រាប់សកម្មភាពក្រុមទិញធាតុចូលនេះ គឺមានចំនួន ៧៨២ ដុល្លារអាមេរិក ដែលរួមបញ្ចូលថ្លៃចំណាយថេរសរុប (១៨៤ ដុល្លារអាមេរិក បានមកពីថ្លៃចំណាយទាំងអស់សម្រាប់ការគាំទ្រដល់សកម្មភាពរបស់ក្រុមទិញធាតុចូល ក្នុងជំហានទី ១ ជំហានទី ២ ជំហានទី ៣ និងជំហានទី ៥) និងថ្លៃចំណាយអថេរ (៥៩៨ ដុល្លារអាមេរិក បានមកពីការចំណាយទាំងអស់សម្រាប់ការគាំទ្រដល់សកម្មភាពរបស់ក្រុមទិញធាតុចូលក្នុងជំហានទី ៤ "ប្រតិបត្តិការក្នុងអំឡុងពេលទិញធាតុចូល" ។ ដូច្នេះ ថ្លៃចំណាយអថេរក្នុងមួយតោនគឺ ២១,៦៧ ដុល្លារអាមេរិក។ ក្នុងករណីនេះ សហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតមិនអាចរ៉ាប់រងលើថ្លៃចំណាយរបស់មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ ដែលពាក់ព័ន្ធនឹងសកម្មភាពរបស់ក្រុមទិញធាតុចូលបានទេ។

រូបភាពទី ១ ៖ ការបង្ហាញក្រាហ្វិកនៃចំណុចរួចដើម




## ៦.២. ចំណុចខ្លាំង និងចំណុចខ្សោយ

បន្ទាប់ពីបញ្ចប់សកម្មភាពក្រុមទិញធាតុចូលនៅសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិត បណ្តាញកសិករ និងទឹក និងមជ្ឈមណ្ឌលសេវាកម្មធារាសាស្រ្ត បានពិនិត្យមើលការអនុវត្តនិងបានកត់ចំណាំពីចំណុចខ្លាំង និងខ្សោយសំខាន់ៗដែលមានដូចខាងក្រោម៖

### ចំណុចខ្លាំង

- សមាជិកមានផែនការច្បាស់លាស់សម្រាប់ទិញជី
- ភាគីទាំងអស់ដែលចូលរួមគោរព និងពិភាក្សាលើវិធីសាស្រ្ត និងគោលការណ៍ដែលឯកភាព
- ភាគីទាំងអស់ដែលចូលរួមមានការប្តេជ្ញាចិត្តខ្ពស់សម្រាប់សកម្មភាពនេះ

### ចំណុចខ្សោយ

- សមត្ថភាពរបស់សមាគមន៍កសិករប្រើប្រាស់ទឹកចំពោះការគ្រប់គ្រងទិន្នន័យនៅមានកម្រិត
- ការទូទាត់យឺតរបស់សមាជិកមួយចំនួនតូច (ពេលនេះបានអនុវត្តពាសពេញ ដោយគ្មានការប្រាក់សម្រាប់ការទូទាត់យឺត)

## ៧. ការធ្វើសាជាថ្មី និងស្ថានភាពសម្រាប់ការធ្វើជាថ្មី ដោយគ្មានជំនួយរបស់គម្រោង SCCRP

## ៧.១. សមត្ថភាព និងដែនកំណត់នៃសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតក្នុងការពង្រីកការអនុវត្តរបស់ក្រុមទិញធាតុចូល

SCCRP ▪ ករណីសិក្សា

មជ្ឈមណ្ឌលសេវាធារាសាស្ត្របានបង្កើតឧបករណ៍ ដើម្បីធ្វើឱ្យងាយស្រួលដល់ការគ្រប់គ្រងរបស់ក្រុមទិញធាតុចូល។ ប៉ុន្តែ ទោះជាសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតមានបទពិសោធន៍ដំបូងពាក់ព័ន្ធនឹងក្រុមទិញជីនេះក៏ដោយ ក៏គេវាយតម្លៃថា សហគមន៍នៅមិនទាន់មានសមត្ថភាពពេញលេញក្នុងការធ្វើសកម្មភាពជាក្រុមទិញជីដោយឯកឯងសម្រាប់រដូវកាលផលិតកម្មស្រូវបន្ទាប់បានឡើយ។

ព័ត៌មានលម្អិតអំពីអ្វីដែលសហគមន៍កសិករប្រើប្រាស់ទឹកអាចអនុវត្តបាន និងអ្វីដែលនៅតែត្រូវការការគាំទ្រពីខាងក្រៅមានផ្តល់ជូនដូចខាងក្រោម៖

អ្វីដែលសហគមន៍កសិករប្រើប្រាស់ទឹកនៅស្ទឹងជីនិតអាចធ្វើដោយឯកឯងបានមានដូចជា៖

- រៀបចំកិច្ចប្រជុំនៅកម្រិតភូមិ ដើម្បីស្វែងរកកសិករដែលមានចំណាប់អារម្មណ៍លើក្រុមទិញធាតុចូល
- ធ្វើផែនការបុគ្គលជាមួយកសិករដែលមានចំណាប់អារម្មណ៍លើក្រុមទិញធាតុចូល
- ប្រាស្រ័យទាក់ទងជាមួយអ្នកផ្គត់ផ្គង់ជី
- ប្រមូលការទូទាត់លើជីពីសមាជិកក្រុមទិញធាតុចូល
- ផ្ទេរការទូទាត់ជីទៅឱ្យអ្នកផ្គត់ផ្គង់ជី។

អ្វីដែលសហគមន៍កសិករប្រើប្រាស់ទឹកនៅស្ទឹងជីនិតមិនអាចធ្វើដោយឯកឯងបានមានដូចជា៖

- ការគ្រប់គ្រងទិន្នន័យរបស់ក្រុមទិញធាតុចូលដូចជា បញ្ចូលទិន្នន័យផែនការបុគ្គលតាមរយៈការប្រើប្រាស់គំរូនៅក្នុងឯកសារ Excel ធ្វើបច្ចុប្បន្នភាពផែនការ និងបញ្ចូលទិន្នន័យការទូទាត់ជីរបស់សមាជិក។

ដំណោះស្រាយដែលបានស្នើឡើងសម្រាប់អ្វីដែលសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតមិនអាចធ្វើដោយឯកឯងបានមានដូចជា៖

- សហគមន៍អាចប្រើប្រាស់សេវាកម្មខាងក្រៅមួយចំនួន (បង់ប្រាក់សម្រាប់ការអនុវត្តភារកិច្ចមួយចំនួនដោយអ្នកផ្តល់សេវាកម្ម)
- សហគមន៍អាចមានលទ្ធភាពជួលបុគ្គលិក ឱ្យអនុវត្តសកម្មភាព។

គេនៅតែត្រូវការការវាយតម្លៃយ៉ាងលម្អិតលើលទ្ធភាពនៃជម្រើសទាំងពីរនេះ។

## ៧.២. សកម្មភាពធ្វើសាជាថ្មីដែលមានភាពមិនច្បាស់លាស់នៅឆ្នាំ ២០១៧

ផ្អែកលើលទ្ធផលនៃការអនុវត្តរបស់ក្រុមទិញជីនៃសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិត គឺមានលក្ខណៈវិជ្ជមានខ្លាំងអំពីបរិមាណដែលពួកគេអាចសន្សំសំចៃលើការទិញជីដោយសារតែក្រុមទិញធាតុចូល។ គេបានពង្រីកសកម្មភាពនេះនៅឆ្នាំ ២០១៧ ហើយបានអនុវត្តម្តងទៀតដោយជោគជ័យដែលបង្ហាញថា ម៉ូដែលនេះនៅមានសុពលភាព។ កសិករចំនួន ២១៩ នាក់បានចូលរួមសកម្មភាពផលិតកម្មស្រូវនេះនៅក្នុងរដូវវស្សានាឆ្នាំ ២០១៧ ។ ពួកគេបានទិញជីចំនួន ៤៩ ៩៧៥ គីឡូក្រាម (សម្រាប់ទឹកប្រាក់ចំនួន ២៨ ១៩៥,៥០ ដុល្លារ) តាមរយៈក្រុមទិញធាតុចូលរបស់សហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិត។ ចំពោះបរិមាណទាំងនេះ គេប៉ាន់ប្រមាណថា សមាជិករបស់ក្រុមទិញធាតុចូលអាចសន្សំប្រាក់បានចំនួន ៣ ២៧២ ដុល្លារ លើការទិញជីរបស់ពួកគេ។ សមាគមន៍កសិករប្រើប្រាស់ទឹកអាចទទួលបានប្រាក់ចំណូលចំនួន ៤៩៩,៧៥ ដុល្លារ ហើយបណ្តាញកសិករ និងទឹកក៏អាចទទួលបានប្រាក់ចំណូល ៤៩៩,៧៥ ដុល្លារផងដែរ។

នៅឆ្នាំ ២០១៧ ក្រុមទិញធាតុចូលនៃសមាគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតបានសហការជាដៃគូជាមួយអ្នកផ្គត់ផ្គង់ជីដូចគ្នាទៅនឹងឆ្នាំ ២០១៦ ដែរ ប៉ុន្តែអ្នកផ្គត់ផ្គង់នេះបានបន្ថយតម្លៃរបស់ខ្លួនបន្ថែមទៀតគឺ ១ ដុល្លារក្នុង ៥០ គីឡូក្រាម សម្រាប់ប្រភេទជីនីមួយៗ។ ចំនួនទឹកប្រាក់ដែលបានសន្សំដោយសមាជិករបស់ក្រុមទិញធាតុចូលនៅឆ្នាំ ២០១៧ គឺខ្ពស់ជាងឆ្នាំមុន (ការកាត់បន្ថយថ្លៃចំណាយលើជីរបស់ពួកគេដែលជាមធ្យម ១២,៨៣%) ហើយសហគមន៍កសិករប្រើប្រាស់ទឹក និងបណ្តាញកសិករ និងទឹក អាចទទួលបានប្រាក់ចំណូលក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងឆ្នាំ ២០១៦ ដែរ (០,៥០ ដុល្លារ ក្នុង ៥០ គីឡូក្រាមចំពោះសហគមន៍កសិករប្រើប្រាស់ទឹក និង ០,៥០ ដុល្លារក្នុង ៥០ គីឡូក្រាម ចំពោះបណ្តាញកសិករ និងទឹក)។